# ការលាតត្រដាងឲ្យដឹងសម្រាប់ការដាក់ពាក្យសុំធ្វើជាអ្នកស្ម័គ្រចិត្ត/DISCLOSURE STATEMENT APPLICATION FOR VOLUNTEERS

**តម្រូវឲ្យដោយច្បាប់ការពារកុមារ/Required by the Child Protective Service Law**

**23 Pa. C.S. មាត្រាលេខ 6344.2 (ទាក់ទងនឹងអ្នកស្ម័គ្រចិត្តដែលធ្វើការជាមួយកុមារ)**

ខ្ញុំសូម ស្បថ/បញ្ជាក់ ថាខ្ញុំសុំធ្វើជាអ្នកស្ម័គ្រចិត្ត ហើយ**គេមិន**តម្រូវឲ្យខ្ញុំសុំលិខិតបញ្ជាក់ពី ក្រសួងស៊ើបអង្កេតរបស់រដ្ឋសហព័ន្ធ (FBI) ទេ ដោយសារៈ

- មុខងារដែលខ្ញុំដាក់ពាក្យស្នើសុំធ្វើការ គឺជាមុខងារដែលគ្មានប្រាក់ខែ **ហើយ**
- ខ្ញុំបានរស់នៅក្នុងរដ្ឋធិនស៊ីលវេនញ៉ាអស់រយៈពេលដប់ឆ្នាំមកហើយ។

ខ្ញុំដឹងថា បើសិនជាខ្ញុំមិនបានរស់នៅក្នុងរដ្ឋធិនស៊ីលវេនញ៉ាគ្រប់រយៈពេលដប់ឆ្នាំទេនោះ ប៉ុន្តែធ្លាប់បានទទួលលិខិតបញ្ជាក់ពី ក្រសួងស៊ើបអង្កេតរបស់រដ្ឋសហព័ន្ធ ចាប់តាំងពីពេលដែលខ្ញុំបានមករស់នៅទីនេះ ខ្ញុំត្រូវតែផ្តល់ច្បាប់ចម្លងនៃលិខិតបញ្ជាក់មួយច្បាប់ទៅឲ្យកន្លែងធ្វើការរបស់ខ្ញុំ ហើយគេមិនតម្រូវឲ្យខ្ញុំសុំលិខិតបញ្ជាក់ពី ក្រសួងស៊ើបអង្កេតរបស់រដ្ឋសហព័ន្ធ បន្ថែមទៀតនោះទេ។

ខ្ញុំសូម ស្បថ/បញ្ជាក់ ថា បើសិនជាបានផ្តល់លិខិតបញ្ជាក់ដែលបានមកក្នុងកំឡុងពេល ៦០ខែ កន្លងទៅនេះ គេមិនដែលបានដកសិទ្ធិធ្វើកិច្ចការ ដូចបានរៀបរាប់ខាងក្រោមនេះ ឬគេមិនដែលបានផ្តន្ទាទោសខ្ញុំពីបទល្មើសស្រដៀងគ្នានឹងបទឧក្រិដ្ឋ ដូចបានរាយនៅក្នុងបញ្ជីខាងក្រោមនេះ តាមច្បាប់ ឬតាមច្បាប់ចាស់ របស់សហរដ្ឋ ឬរបស់តំបន់ដែលសហរដ្ឋត្រួតត្រា ឬក្រោមការកាន់កាប់របស់សហរដ្ឋ រដ្ឋផ្សេងទៀត រដ្ឋវ៉ាស៊ីងតោន DC ច្បាប់របស់ប្រជាជាតិព័រតូរីកូ ឬ ច្បាប់របស់បរទេស ឬក្រោមច្បាប់ចាស់របស់ប្រជាពលរដ្ឋនេះ។

ខ្ញុំសូម ស្បថ/បញ្ជាក់ ថា គេមិនដែលបានដាក់កំហុសខ្ញុំថាជាឧក្រិដ្ឋជននៅក្នុងរបាយការណ៍ណាមួយ ពីបទធ្វើបាបក្មេង នៅក្នុងរយៈពេលប្រាំ (៥) ឆ្នាំកន្លងទៅនេះ ដូចបានឲ្យនិយមន័យដោយច្បាប់ការពារក្មេង (**Child Protective Service Law**)។

ខ្ញុំសូម ស្បថ/បញ្ជាក់ ថា គេមិនដែលបានកាត់ទោសខ្ញុំពីបទឧក្រិដ្ឋអ្វីមួយដូចមានខាងក្រោមនេះ តាមច្បាប់ Title 18 នៃច្បាប់រដ្ឋធិនស៊ីលវេញ៉ា ដែលជាច្បាប់រួម ឬបទល្មើសដែលស្រដៀងគ្នានឹងបទឧក្រិដ្ឋទាំងនោះ តាមច្បាប់ ឬច្បាប់ចាស់ របស់សហរដ្ឋ ឬរបស់តំបន់ដែលសហរដ្ឋត្រួតត្រា ឬក្រោមការកាន់កាប់របស់សហរដ្ឋ រដ្ឋផ្សេងទៀត រដ្ឋវ៉ាស៊ីងតោន DC ច្បាប់របស់ប្រជាជាតិព័រតូរីកូ ឬ ច្បាប់របស់បរទេស ឬក្រោមច្បាប់ចាស់របស់ប្រជាពលរដ្ឋនេះ។

ជំពូក ២៥ (ដែលទាក់ទងនឹងឧក្រិដ្ឋកម្ម)/ Chapter 25 (relating to criminal homicide)
មាត្រាលេខ ២៧០២ (ដែលទាក់ទងនឹងការវាយតប់គេយ៉ាងធ្ងន់ធ្ងរ)/ Section 2702 (relating to aggravated assault)
មាត្រាលេខ ២៧០៩,១ (ដែលទាក់ទងនឹងការលួចតាមដានគេ)/ Section 2709.1 (relating to stalking)
មាត្រាលេខ ២៩០១ (ដែលទាក់ទងនឹងការចាប់ជំរិត)/ Section 2901 (relating to kidnapping)
មាត្រាលេខ ២៩០២ (ដែលទាក់ទងនឹងការឃុំឃាំងគេដោយខុសច្បាប់)/ Section 2902 (relating to unlawful restraint)
មាត្រាលេខ ៣១២១ (ដែលទាក់ទងនឹងការរំលោភ)/ Section 3121 (relating to rape)
មាត្រាលេខ ៣១២២,១ (ដែលទាក់ទងនឹងការរំលោភក្មេងមិនទាន់គ្រប់អាយុ)/ Section 3122.1 (relating to statutory sexual assault)
មាត្រាលេខ ៣១២៣ (ដែលទាក់ទងនឹងការបង្ខំសេពមេថុនដោយប្រើរបស់ផ្សេងៗ)/ Section 3123 (relating to involuntary deviate sexual intercourse)
មាត្រាលេខ ៣១២៤,១ (ដែលទាក់ទងនឹងការរំលោភលើផ្លូវភេទ)/ Section 3124.1 (relating to sexual assault)
មាត្រាលេខ ៣១២៥ (ដែលទាក់ទងនឹងការរំលោភបំពានធ្ងន់ធ្ងរលើផ្លូវភេទ)/ Section 3125 (relating to aggravated indecent assault)
មាត្រាលេខ ៣១២៦ (ដែលទាក់ទងនឹងការប៉ះពាល់បំពានលើផ្លូវភេទ)/ Section 3126 (relating to indecent assault)
មាត្រាលេខ ៣១២៧ (ដែលទាក់ទងនឹងការបង្ហាញប្រដាប់ភេទដោយមិនសមរម្យ)/ Section 3127 (relating to indecent exposure)
មាត្រាលេខ ៤៣០២ (ដែលទាក់ទងនឹងការសេពមេថុនជាមួយសាច់ញាតិ)/ Section 4302 (relating to incest)
មាត្រាលេខ ៤៣០៣ (ដែលទាក់ទងនឹងការលាក់បាំងមរណភាពរបស់កុមារ)/ Section 4303 (relating to concealing death of child)
មាត្រាលេខ ៤៣០៤ (ដែលទាក់ទងនឹងការធ្វើឲ្យមានគ្រោះថ្នាក់ដល់កុមារ)/ Section 4304 (relating to endangering welfare of children)
មាត្រាលេខ ៤៣០៥ (ដែលទាក់ទងនឹងលក់ដូរក្មេង)/ Section 4305 (relating to dealing in infant children)
មាត្រាលេខ ៥៩០២(b) (ដែលទាក់ទងនឹងពេស្យាចារ និងបទល្មើសដែលពាក់ព័ន្ធ)/ Section 5902(b) (relating to prostitution and related offenses)
មាត្រាលេខ ៥៩០៣(c) (d) (ដែលទាក់ទងនឹងអាសគ្រាម និងសម្ភារៈ និងការសេពថុន ផ្សេងៗទៀត/ Section 5903(c) (d) (relating to obscene and other sexual material and performances)
មាត្រាលេខ ៦៣០១ (ដែលទាក់ទងនឹងការនាំឲ្យក្មេងខូច)/ Section 6301 (relating to corruption of minors)
មាត្រាលេខ ៦៣១២ (ដែលទាក់ទងនឹងការធ្វើបាបទៅលើផ្លូវភេទរបស់ក្មេង) ឬ បទឧក្រិដ្ឋស្មើគ្នា ក្រោមច្បាប់រដ្ឋសហព័ន្ធ ឬច្បាប់នៅរដ្ឋផ្សេងទៀត/ Section 6312 (relating to sexual abuse of children), or an equivalent crime under Federal law or the law of another state.

ខ្ញុំសូម ស្បថ/បញ្ជាក់ ថាខ្ញុំមិនដែលទទួលការផ្តន្ទាទោសនៃបទឧក្រិដ្ឋក្រោមច្បាប់ Act 64-1972 (ដែលទាក់ទងនឹង គ្រឿងបរិក្ខារពេទ្យ និងការកែសម្ផស្ស) ដែលកើតមានក្នុងកំឡុងពេលប្រាំឆ្នាំកន្លងទៅនេះ។

ខ្ញុំដឹងថា គេនឹងមិនយល់ព្រមឲ្យខ្ញុំធ្វើការទេ បើសិនជាខ្ញុំមានឈ្មោះថាជាឧក្រិដ្ឋជនដែលមាននៅក្នុងរបាយការណ៍នៃការធ្វើបាបកុមារ ក្នុងកំឡុងពេលប្រាំ (៥) ឆ្នាំកន្លងទៅនេះ ឬធ្លាប់បានគេផ្តន្ទាទោស ដោយបទឧក្រិដ្ឋអ្វីមួយ ដែលបានរៀបរាប់មកខាងលើនេះ ឬបទល្មើសដែលស្រដៀងគ្នានឹងបទឧក្រិដ្ឋទាំងនោះ ក្រោមច្បាប់ ឬច្បាប់ចាស់ របស់សហរដ្ឋ ឬរបស់តំបន់ដែលសហរដ្ឋត្រួតត្រា ឬក្រោមការកាន់កាប់របស់សហរដ្ឋ រដ្ឋផ្សេងទៀត រដ្ឋវ៉ាស៊ីងតោន DC ច្បាប់របស់ប្រជាជាតិព័រតូរីកូ ឬ ច្បាប់របស់បរទេស ឬក្រោមច្បាប់ចាស់របស់ប្រជាពលរដ្ឋនេះ។

ខ្ញុំដឹងថា បើសិនជាខ្ញុំត្រូវគេចាប់ខ្លួន ឬបានផ្តន្ទាទោស ដោយបទឧក្រិដ្ឋអ្វីមួយដែលអាចឲ្យគេបដិសេធការចូលរួមក្នុង កម្មវិធី សកម្មភាព ឬការបម្រើ អ្វីមួយក្រោមច្បាប់ការពារកុមារ ដូចបានរៀបរាប់មកខាងលើនេះ ឬ មានឈ្មោះថាជាឧក្រិដ្ឋជនដែលមាន ឬបង្ហាញ នៅក្នុងរបាយការណ៍ ខ្ញុំត្រូវតែផ្តល់ឲ្យរដ្ឋបាល ឬ អ្នកតំណាង តាមរយៈការសរសេរលិខិត មិនឲ្យហួស៧២ម៉ោង ក្រោយពីមានការចាប់ខ្លួន ការផ្តន្ទាទោស ឬការផ្តល់ដំណឹង ថាគេបានចុះឈ្មោះខ្ញុំជាឧក្រិដ្ឋជននៅក្នុងប្រព័ន្ធទិន្នន័យទូទាំងរដ្ឋ។

ខ្ញុំដឹងថា បើសិនជាអ្នកទទួលខុសត្រូវក្នុងការសម្រេចចិត្តឲ្យធ្វើការ ឬរដ្ឋបាលនៃ កម្មវិធី សកម្មភាព ឬ ការបម្រើ មានជំនឿសមហេតុផលថា គេចាប់ខ្លួនខ្ញុំ ឬផ្តន្ទាទោសនូវបទឧក្រិដ្ឋដែលគេអាចបដិសេធការចូលរួមក្នុង កម្មវិធី សកម្មភាព ឬ ការបម្រើ ក្រោមច្បាប់ការពារកុមារ ឬមានឈ្មោះថាជាឧក្រិដ្ឋជនដែលមាន ឬបង្ហាញ នៅក្នុងរបាយការណ៍ ឬ ខ្ញុំបានផ្តល់ដំណឹងតាមការតម្រូវក្រោមមាត្រានេះ អ្នកទទួលខុសត្រូវក្នុងការសម្រេចចិត្តឲ្យធ្វើការ ឬ រដ្ឋបាលនៃ កម្មវិធី សកម្មភាព ឬ ការបម្រើ នឹងតម្រូវឲ្យខ្ញុំផ្តល់ការបញ្ជាក់ថ្មីៗដែលបានមកពី ក្រសួងបម្រើប្រជាពលរដ្ឋ (Department of Human Services) ប៉ូលីសរដ្ឋផិនស៊ីលវេញ៉ា (Pennsylvania State Police) និង ក្រសួងស៊ើបអង្កេតរបស់រដ្ឋសហព័ន្ធ (Federal Bureau of Investigation) ជាបន្ទាន់ តាមលក្ខណៈសមរម្យ។ តម្លៃនៃលិខិតបញ្ជាក់ត្រូវរ៉ាប់រងដោយកន្លែងជួលអ្នកធ្វើការ ឬ កម្មវិធី សកម្មភាព ឬ ការបម្រើ។

ខ្ញុំដឹងថា បើសិនជាខ្ញុំលាក់បាំងព័ត៌មានដែលគេតម្រូវឲ្យដូចខាងលើនេះដោយចេតនា ខ្ញុំប្រព្រឹត្តិបទល្មើសនៃកម្រិតទីបី ហើយនឹងមានការដាក់វិន័យរហូតដល់ រួមទាំងការបដិសេធមុខងារជាអ្នកស្ម័គ្រចិត្ត។

ខ្ញុំដឹងថា លិខិតបញ្ជាក់ដែលបានមកសម្រាប់ការធ្វើជាអ្នកស្ម័គ្រចិត្ត អាចប្រើសម្រាប់តែគោលបំណងនៃការងារនេះតែប៉ុណ្ណោះ។

ខ្ញុំដឹងថា គេតម្រូវឲ្យ អ្នកទទួលខុសត្រូវក្នុងការសម្រេចចិត្តឲ្យធ្វើការ ឬរដ្ឋបាលនៃ កម្មវិធី សកម្មភាព ឬ ការបម្រើ រក្សាលិខិតបញ្ជាក់របស់ខ្ញុំមួយច្បាប់។

ខ្ញុំសូម ស្បថ/បញ្ជាក់ ថាព័ត៌មានដែលមានដូចខាងលើនេះទាំងប៉ុន្មាន គឺជាការពិត និងត្រឹមត្រូវ។ ខ្ញុំដឹងថា សម្បថដែលមិនពិតគឺជាបទល្មើសក្រោមមាត្រាលេខ 4903 នៃច្បាប់ឧក្រិដ្ឋកម្ម។

ឈ្មោះ៖ ____________________________ ហត្ថលេខា៖ ________________________________

សាក្សី៖ ____________________________ ហត្ថលេខា៖ ________________________________

ថ្ងៃខែ៖ ______________________